**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២៥២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៩.០៦៧ ហិកតា នៅស្រុករលាប្អៀរ ស្រុកទឹកផុស ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ក្នុងនោះ កាត់ចេញពីដីអតីតសហគ្រាសសេរី កាត់ចេញពីដីសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុន គាពីម៉ិច និងកាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤.៥៤៩ គ្រួសារ និងរក្សាមួយចំណែកជាដីសហគមន៍ និងជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ



www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៩៧៣ លស ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.**

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ៩.០៦៧ ហិកតា ក្នុងនោះ (១) ទំហំ ៦៣៤ ហិកតា កាត់ចេញពីដីអតីតសហគ្រាសសេរី (២) ទំហំ ៨.០១៧ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច និង (៣) ទំហំ ៤១៦ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មទំហំ ៨.៣៨៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៦៧៨ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិសាស្ត្រដូចខាងក្រោម៖

១. ឃុំពង្រ ស្រុករលាប្អៀរ

- ផ្ទៃដីទំហំ ១២៤ ហិកតា កាត់ចេញពីដីអតីតសហគ្រាសសេរី សម្រាប់ប្រទានកម្មទំហំ ១១១ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៣ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិត្រពាំងធំ ។
- ផ្ទៃដីទំហំ ១៦៤ ហិកតា កាត់ចេញពីដីអតីតសហគ្រាសសេរី សម្រាប់ប្រទានកម្មទំហំ ១៤៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិថ្នារប ។

២.ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ

- ផ្ទៃដីទំហំ ២៥៤ ហិកតា កាត់ចេញពីដីអតីតសហគ្រាសសេរី សម្រាប់ប្រទានកម្មទំហំ ២៤៤ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១០ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិស្វាយចេក ។
- ផ្ទៃដីទំហំ ៩២ ហិកតា កាត់ចេញពីដីអតីតសហគ្រាសសេរី សម្រាប់ប្រទានកម្មទំហំ ៨៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ០៤ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិស្វាយជ្រុំថ្មី ។

៣.ឃុំក្បាលទឹក ស្រុកទឹកផុស

- កាត់ផ្ទៃដីសរុបទំហំ ៩៨៩ ហិកតា ក្នុងនោះ (១) ទំហំ ៥៧៣ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច និង (២) ទំហំ ៤១៦ ហិកតា កាត់ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ សម្រាប់ប្រទានកម្មទំហំ ៩២៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៦៤ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងជាដីសាធារណៈរបស់រដ្ឋ នៅភូមិខ្ទិតទួលឃ្លាំង

៤.ឃុំក្រាំងស្គារ ស្រុកទឹកផុស

- ផ្ទៃដីទំហំ ៥.៨៥៣ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ប្រទានកម្មទំហំ ៥.៤៣១ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៤២២ ហិកតា រក្សាទុកសម្រាបសហគមន៍ព្រៃឈើ នឹងជាដីសាធារណៈរបសរដ្ឋ នៅភូមិអញ្ចាញ

៥.ឃុំចោងម៉ោង ស្រុកទឹកផុស

- ផ្ទៃដីទំហំ ៣៧៧ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ប្រទានកម្មទំហំ ៣៣០ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៤៧ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងជាដីសាធារណៈរបស់រដ្ឋ នៅភូមិអលង្កែរ
- ផ្ទៃដីទំហំ ១២៤ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ប្រទានកម្មទំហំ ១១០ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៤ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងជាដីសាធារណៈរបស់រដ្ឋ នៅភូមិត្រពាំងជុំ

៦.ឃុំទួលខ្ពស់ ស្រុកទឹកផុស

- ផ្ទៃដីទំហំ ៧០៥ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ប្រទានកម្មទំហំ ៦៣៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៦៧ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងជាដីសាធារណៈរបស់រដ្ឋ នៅភូមិត្រពាំងស្នាច់

៧.ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ

- ផ្ទៃដីទំហំ ១៦០ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ប្រទានកម្មទំហំ ១៥៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៥ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងជាដីសាធារណៈរបស់រដ្ឋ នៅភូមិត្រពាំងទំលាប់ ។



www.pheakdeylaw.com

- ផ្ទៃដីទំហំ ២២៥ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ប្រទានកម្មទំហំ ២០៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ១៧ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងជាដីសាធារណៈរបស់រដ្ឋ នៅភូមិព្រៃញាម

តាមប្រព័ន្ធកូអរដោនេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ១-ឧបសម្ព័ន្ធ៧ នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ៤.៥៤៩ គ្រួសារ និងទំហំ ៦៧៨ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិសាស្ត្រដូចខាងក្រោម៖

១.ឃុំពង្រ ស្រុករលាប្អៀរ

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៨៨ គ្រួសារ នៅភូមិត្រពាំងធំ ។
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៩៦ គ្រួសារ នៅភូមិថ្នរាប ។

២.ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៧៥ គ្រួសារ នៅភូមិស្វាយចេក ។
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣២៨ គ្រួសារ នៅភូមិស្វាយជ្រុំថ្មី ។

៣.ឃុំក្បាលទឹក ស្រុកទឹកផុស

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៦២ គ្រួសារ នៅភូមិខ្ទិតទួលឃ្លាំង ។

៤.ឃុំក្រាំងស្គារ ស្រុកទឹកផុស

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.១៥៥ គ្រួសារ នៅភូមិអញ្ចាញ ។

៥.ឃុំចោងម៉ោង ស្រុកទឹកផុស

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៩៩ គ្រួសារ នៅភូមិអលង្គែរ ។
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២១៦ គ្រួសារ នៅភូមិត្រពាំងជុំ ។

៦.ឃុំទួលខ្ពស់ ស្រុកទឹកផុស

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៧០ គ្រួសារ នៅភូមិត្រពាំងស្នាច់ ។

៧.ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៩៣ គ្រួសារ នៅភូមិត្រពាំងទំលាប់ ។
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៧៧ គ្រួសារ នៅភូមិព្រៃញាម ។



www.pheakdeylaw.com

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែឧសភា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com